**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ផ្ទៃដីទំហំសរុប ១១១,៤៩ហិកតា ចេញពីផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាប ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅក្រុងសៀមរាប ខេត្តសៀមរាប

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែង គ្រប់គ្រងតំបន់សៀមរាបអង្គរ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីអំពីបុរីសណ្ឋាគារ
- បានឃើញអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការពង្រីកផ្ទៃដីបុរីសណ្ឋាគារអង្គរ សៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**មាត្រា ១._**

ត្រូវបានកាត់ផ្ទៃដីទំហំសរុប ១១១,៤៩ហិកតា ចេញពីផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាបដែលគ្រប់គ្រងដោយអាជ្ញាធរអប្សរាដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង នៅក្រុងសៀមរាប ខេត្តសៀមរាប ក្នុងភូមិ សង្កាត់ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ១០១,២៣ហិកតា កាត់ចេញពីផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាបសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិព្រៃគុយ សង្កាត់អំពិល តាមប្រព័ន្ធកូអរដោនេ និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ(១)នៃអនុក្រឹត្យនេះ។
- ផ្ទៃដីទំហំ ១០,២៦ហិកតា កាត់ចេញពីផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាបសម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិគោកចាន់ សង្កាត់អំពិល តាមប្រព័ន្ធកូអរដោនេ និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ(២)នៃអនុក្រឹត្យនេះ។

**មាត្រា ២._**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋគ្រប់គ្រងដោយអាជ្ញាធរអប្សរាដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តសៀមរាប ដើម្បីគ្រប់គ្រង និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រៃគុយ និងភូមិគោកចាន់ សង្កាត់អំពិល ក្រុងសៀមរាប ខេត្តសៀមរាប។

**មាត្រា ៣._**

ក្នុងដំណើរការចុះបញ្ជី ដើម្បីផ្តល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុជូនប្រជាពលរដ្ឋ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តសៀមរាប ត្រូវកាត់ចេញនូវចំណែកផ្ទៃដី ដែលអាជ្ញាធរអប្សរាបានដោះស្រាយគោលនយោបាយរួចរាល់ ដើម្បីរក្សាទុកសម្រាប់ប្រើប្រាស់ជាផលប្រយោជន៍សាធារណៈ។

**មាត្រា ៤._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គនាយកអាជ្ញាធរអប្សរា និងអភិបាល នៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- -ក្រសួងព្រះបរមរាជវាំង
- -ក្រសួងមហាផ្ទៃ
- -ក្រសួងការពារជាតិ
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការ រាជរដ្ឋាភិបាល
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចប្រការ ៥
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com

